# កិច្ចព្រមព្រៀងនិងលក្ខខណ្ឌប្រើប្រាស់ “Hotlineសម្រាប់ដៃគូអាជីវកម្ម” របស់អ៊ីអន

កិច្ចព្រមព្រៀងនិងលក្ខខណ្ឌប្រើប្រាស់នេះ(តទៅនេះ ហៅថា “កិច្ចព្រមព្រៀងនេះ”) កំណត់អំពីលក្ខខណ្ឌប្រើប្រាស់ “Hotlineសម្រាប់ដៃគូអាជីវកម្ម” របស់អ៊ីអន (រួមទាំងកម្មវិធី Genba-Wise (តទៅនេះ ហៅថា “Genba-Wise”)ដែលជាកម្មវិធីទូរស័ព្ទដៃ APPសម្រាប់ទូរស័ព្ទដៃទំនើបផ្តល់ឲ្យដោយASSC) (តទៅនេះហៅរួមគ្នាថា “Hotlineសម្រាប់ដៃគូអាជីវកម្ម”) ដែលផ្តល់ឲ្យដោយក្រុមហ៊ុនអ៊ីអន (តទៅនេះ ហៅថា “អ៊ីអន”) និងអង្គការឌឹ ហ្គ្លូបល់ អឺឡៃអាន់ស៏ ហ្វ៊រ សាស់ស្ទែនណឺបល់ ស៊ីប្លាយឆេន )The Global Alliance For Sustainable Supply Chain) (តទៅនេះ ហៅថា “ASSC”) រវាងអ្នកប្រើប្រាស់ “Hotlineសម្រាប់ដៃគូអាជីកម្ម” (តទៅនេះ ហៅថា “អ្នកប្រើប្រាស់”) និងអ៊ីអន។

## មាត្រា ១ (ឯកភាពនឹងកិច្ចព្រមព្រៀងនិងលក្ខខណ្ឌប្រើប្រាស់)

1. អ្នកប្រើប្រាស់ ត្រូវប្រើHotlineសម្រាប់ដៃគូអាជីវកម្ម ដោយគោរពតាមគោលការណ៍ការពារព័ត៌មានឯកជនភាព) និង កិច្ចព្រមព្រៀងនេះ ជាដាច់ខាត។
2. ករណីអ្នកប្រើប្រាស់ជាអានីតិជន សូមប្រើHotlineសម្រាប់ដៃគូអាជីវកម្ម បន្ទាប់ពីបានទទួលការយល់ព្រមពីអ្នកតំណាងស្របច្បាប់ ឬ អាណាព្យាបាល ជាដើម (រួមទាំង ការឯកភាពនឹងកិច្ចព្រមព្រៀងនេះផង)។ម្យ៉ាងទៀត គ្រាន់តែពេលមានការយល់ព្រមនឹងកិច្ចព្រមព្រៀងនេះភ្លាម នោះចាត់ទុកថា អ្នកប្រើប្រាស់ដែលជាអានីតិជននោះ ទទួលស្គាល់នូវរាល់សកម្មភាពដែលខ្លួនបានប្រើHotlineសម្រាប់ដៃគូអាជីវកម្ម ក្នុងចន្លោះពេលខ្លួននៅជាអានីតិជន ករណីគេនៅតែបន្តប្រើHotlineសម្រាប់ដៃគូអាជីវកម្ម ក្រោយពេលពេញវ័យ។
3. ករណីមានកិច្ចព្រមព្រៀងដាច់ដោយឡែកក្នុងការប្រើប្រាស់ “Hotlineសម្រាប់ដៃគូអាជីវកម្ម” អ្នកប្រើប្រាស់ត្រូវតែប្រើប្រាស់ “Hotlineសម្រាប់ដៃគូអាជីវកម្ម” ដោយគោរពតាមកិច្ចព្រមព្រៀងនេះ ព្រមទាំងការកំណត់ក្នុងកិច្ចព្រមព្រៀងដាច់ដោយឡែកនោះផង។

## មាត្រា ២ (ការកែប្រែកិច្ចព្រមព្រៀង)

1. អ៊ីអន មានសិទ្ធិកែប្រែកិច្ចព្រមព្រៀងនេះ តាមពេលវេលាចាំបាច់ ដោយស្របតាមច្បាប់រដ្ឋប្បវេណី ចំណុចទី4 មាត្រា៥៤៨ ក្នុងករណីណាមួយក្នុងចំណោមករណីខាងក្រោមត្រូវបានអនុវត្ត។ កិច្ចព្រមព្រៀងក្រោយធ្វើការកែប្រែ នឹងត្រូវយកមកអនុវត្តចំពោះ “Hotlineសម្រាប់ដៃគូអាជីវកម្ម” ក្រោយពេលកិច្ចព្រមព្រៀងត្រូវបានកែប្រែ។

    (1) ពេលការកែប្រែកិច្ចព្រមព្រៀងនេះ បានជាប្រយោជន៍ដល់អ្នកប្រើប្រាស់ទូទៅ
    (2) ពេលការកែប្រែកិច្ចព្រមព្រៀងនេះ ឥតមានអ្វីផ្ទុយនឹងគោលបំណងនៃការចុះកិច្ចព្រមព្រៀង ព្រមទាំងមានភាពចាំបាច់ត្រូវការកែប្រែ និងភាពសមប្រកបចំពោះអត្ថន័យក្រោយពេលកែប្រែ ព្រមទាំងមានភាពសមស្របតាមសភាពការជាក់ស្តែងដែលពាក់ព័ន្ធនឹងអត្ថន័យនោះឬការកែប្រែផ្សេងៗទៀត។

2. ក្នុងករណីអ៊ីអនធ្វើការកែប្រែកិច្ចព្រមព្រៀងនេះ អ៊ីអននឹងកំណត់កាលបរិច្ឆេទដែលកិច្ចព្រមព្រៀងក្រោយពេលធ្វើការកែប្រែចាប់មានសុពលភាព ហើយជូនដំណឹងពីអត្ថន័យនិងកាលបរិច្ឆេទចាប់មានសុពលភាពនៃ

កិច្ចព្រមព្រៀងនេះក្រោយពេលធ្វើការកែប្រែ ដល់អ្នកប្រើប្រាស់ឲ្យបាន1សប្តាហ៍មុនពេលចាប់ផ្តើមមានសុពលភាព ព្រមទាំងប្រកាសជាសាធារណៈនៅទីតាំងសមរម្យណាមួយក្នុងគេហទំព័រគ្រប់គ្រងដោយអ៊ីអន ឬ នៅលើ Hotlineសម្រាប់ដៃគូអាជីវកម្ម និងជូនដំណឹងដល់អ្នកប្រើប្រាស់តាមមធ្យោបាយជាក់លាក់ណាមួយផ្សេងទៀត។

3. ទោះបីមានបញ្ញត្តិក្នុងកាថាខណ្ឌទាំង2ខាងលើក៏ដោយ ប្រសិនបើអ្នកប្រើប្រាស់នៅតែបន្តប្រើ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ក្រោយពេលធ្វើការកែប្រែ ឬក៏អ្នកប្រើប្រាស់ឥតបានផ្តាច់កិច្ចសន្យាក្នុងចន្លោះពេលដែលអ៊ីអនបានកំណត់ នោះចាត់ទុកថាអ្នកប្រើប្រាស់ពាក់ព័ន្ធយល់ព្រមនឹងការកែប្រែកិច្ចព្រមព្រៀងនេះ។

4. អ្នកប្រើប្រាស់ណាដែលប្រើប្រាស់ផ្ទុយនឹងកិច្ចព្រមព្រៀងនេះត្រូវចុះកិច្ចសន្យាកែប្រែដាច់ដោយឡែកជាមួយអ៊ីអន ស្តីពីចំនុច ខុសគ្នានោះ។

## មាត្រា ៣ (អត្ថន័យទូទៅនៃសេវា)

អ្នកប្រើប្រាស់ អាចប្រើសេវាកម្ម ដែលមានចែងនៅក្នុងកិច្ចព្រមព្រៀងនេះ ហើយដែលផ្តល់ឲ្យដោយអ៊ីអនក្នុងឈ្មោះ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ឬសេវាផ្សេងទៀតដែលអ៊ីអនផ្តល់ឲ្យដាច់ដោយឡែក ក្នុងនោះមានជាអាទិ៍ ដូចជា៖ ការឆ្លើយតបទៅនឹងការពិគ្រោះពីសំណាក់ភាគីអ្នកប្រើប្រាស់, ការផ្តល់អនុសាសន៍កែលម្អកន្លែងធ្វើការ និងការចែករំលែកបញ្ហាជាមួយគ្នា និងការចុះទៅធ្វើការសិក្សាអង្កេតដល់កន្លែង, ការដាក់របាយការណ៍ និង លើកសំណើរស្តីពីវិធានការដោះស្រាយ ជូនដល់អ៊ីអន, ការវិភាគនិងការរៀបចំកសាងកម្មវិធីស្តុកទិន្នន័យ(Database), ការផ្តល់ព័ត៌មានប្រយោជន៍ជាសាធារណៈដល់ នគរបាល កងកម្លាំងពន្លត់អគ្គីភ័យ និង ក្រុមសង្គ្រោះបន្ទាន់ជាដើម នាគ្រាអាសន្ន, ការជួយសង្គ្រោះដល់អ្នកប្រើប្រាស់ដូចជាការរៀបចំបង្កើតក្រុមពិភាក្សាផ្ទៃក្នុងអ៊ីអន។ល។ លើសពីនេះទៀត ការប្រើ "Hotlineសម្រាប់ដៃគូអាជីវកម្ម" តាមទូរស័ព្ទឥតគិតថ្លៃ (Toll-Free Call) វាជាបន្ទុករបស់អ៊ីអន រីឯថ្លៃសេវាទូរគមនាគមន៍ដែលត្រូវការចាំបាច់ក្នុងការធ្វើទំនាក់ទំនង ទទួលអ៊ីម៉ែល បើកមើលគេហទំព័រ។ល។ ជាបន្ទុករបស់អ្នកប្រើប្រាស់ទាំងស្រុង។

## មាត្រា ៤ (លក្ខខណ្ឌប្រើប្រាស់ Genba-Wise)

1. ករណីមានការរក្សាទុកពាក្យសម្ងាត់ នាពេលប្រើ Genba-Wise អ្នកប្រើប្រាស់ Genba-Wise ត្រូវធ្វើការគ្រប់គ្រងឲ្យបានហ្មត់ចត់ ដោយទំនួលខុសត្រូវផ្ទាល់ខ្លួន ជៀសវាងកុំឲ្យគេយកទៅប្រើក្នុងផ្លូវខុស។ ASSC ចាត់ទុកថា៖ រាល់អំពើទាំងឡាយដែលបានប្រព្រឹត្តិ ដោយប្រើពាក្យសម្ងាត់រក្សាទុកនោះ ជាអំពើរបស់សាមីខ្លួនអ្នកប្រើប្រាស់។
2. អ្នកប្រើប្រាស់ ដែលបានចុះឈ្មោះប្រើ Genba-Wise អាចលុបគណនីរបស់ខ្លួន ឈប់ប្រើពេលណាក៏បានដែរ។
3. ករណីអ្នកប្រើប្រាស់ បានទទួលស្គាល់ថាខ្លួនបានបំពាន ឬ អាចមានករណីបំពានលើកិច្ចព្រមព្រៀងនេះ ASSC មានសិទ្ធិ ផ្អាក ឬ លុបគណនីរបស់អ្នកប្រើប្រាស់នោះបាន ដោយមិនចាំបាច់ជូនដំណឹងជាមុនទេ។
4. សិទ្ធិប្រើប្រាស់ Genba-Wise ទាំងអស់របស់អ្នកប្រើប្រាស់ នឹងត្រូវនរាករណ៍ភ្លាម នាពេលគណនីនោះត្រូវបានគេលុបចោល ទោះស្ថិតក្នុងមូលហេតុយ៉ាងណាក៏ដោយ។ ទោះក្នុងករណីអ្នកប្រើប្រាស់ច្រលំលុបគណនី

ដោយខ្លួនឯងក៏ដោយ ក៏គណនីនោះមិនអាចសង្គ្រោះយកមកវិញបានទេ អាស្រ័យដូច្នេះ សូមមេត្តាប្រុងប្រយ័ត្នខ្ពស់។

5. គណនី Genba-Wise ជាកម្មសិទ្ធិផ្តាច់មុខរបស់អ្នកប្រើប្រាស់។ សិទ្ធិប្រើប្រាស់ Genba-Wise ទាំងអស់របស់អ្នកប្រើប្រាស់ មិនត្រូវផ្ទេរ ឲ្យខ្ចី ឬស្នងបន្ត ទៅតតិយជនជាដាច់ខាត។
6. អ្នកមិនអាចថតចម្លង គណនី Genba-Wise ផ្ទាល់ខ្លួន ជាច្រើនគណនីបានទេ។
7. ករណីគណនី Genba-Wise ផ្ទាល់ខ្លួនរបស់អ្នក ត្រូវបានផ្អាកដោយ ASSC នោះអ្នកមិនអាចបង្កើតគណនីថ្មីមួយទៀត ដោយគ្មានការអនុញ្ញាតពី ASSC បានឡើយ។

មាត្រា ៥ (ការផ្តល់សេវា)

1. អ្នកប្រើប្រាស់ ត្រូវត្រៀមឧបករណ៍ឆ្លាតទំនើប ឧបករណ៍ទំនាក់ទំនងព័ត៌មាន ប្រព័ន្ធOS មធ្យោបាយទំនាក់ទំនង ព្រមទាំង អគ្គិសនី។ល។ នៅពេលប្រើកម្មវិធី Genba-Wise ដោយទំនួលខុសត្រូវ និងទំនុកចិត្តខ្លួនឯង ឬអ៊ីអន។ រីឯ ករណីអ្នកប្រើប្រាស់ជាអានីតិជន សូមប្រើតែឧបករណ៍ណា ដែលអ្នកតំណាងស្របច្បាប់ដូចជា អ៊ីអន ឬអាណាព្យាបាលជាដើម បានយល់ព្រមអនុញ្ញាតឲ្យប្រើ តែប៉ុណ្ណោះ។
2. អ៊ីអន អាចកម្រិតសេវា "Hotlineសម្រាប់ដៃគូអាជីវកម្ម" ទាំងអស់ ឬ មួយផ្នែក ដោយយោងតាម អាយុ ការមានឬគ្មានការបញ្ជាក់ទទួលស្គាល់ពីសាមីខ្លួន ការមានឬគ្មានព័ត៌មានទាំងឡាយដែលអ្នកប្រើប្រាស់បានផ្តល់ឲ្យ អ៊ីអនឬASSC (តទៅនេះ ហៅថា "ព័ត៌មានចុះឈ្មោះ") ក្នុងគោលបំណងដើម្បីទទួលសេវាអ្នកប្រើប្រាស់ ហើយបន្ថែមពីលើនេះទៀត អាចកម្រិតត្រឹមតែអ្នកប្រើប្រាស់ណា ដែលអ៊ីអនឬASSC វិនិច្ឆ័យថាបានបំពេញតាមលក្ខខណ្ឌចាំបាច់ តែប៉ុណ្ណោះ។
3. អ្នកប្រើប្រាស់ ត្រូវប្រើប្រាស់ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ក្នុងដែនកំណត់ដែលអ៊ីអននិងASSCបានកំណត់ ស្របតាមលក្ខខណ្ឌពាក់ព័ន្ធ ក្រោយពេលបានពិនិត្យបញ្ជាក់ទទួលស្គាល់លក្ខខណ្ឌនានាដែលបានកំណត់ដោយអ៊ីអននិងASSC ដូចជា ឈ្មោះ អត្តន័យ អាយុ ឬ បរិស្ថានប្រើប្រាស់ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ។ល។
4. អ៊ីអន មានសិទ្ធិ កំណត់ កែប្រែ ឈ្មោះ ព្រមទាំងដែនកំណត់ប្រើប្រាស់នៃ "Hotlineសម្រាប់ដៃគូអាជីវកម្ម" បាន ដោយមិនចាំបាច់ជូនដំណឹងដល់អ្នកប្រើប្រាស់ជាមុនទេ ទោះក្នុងមូលហេតុណាក៏ដោយ។ម្យ៉ាងទៀត អ៊ីអននិងASSC មានសិទ្ធិ កំណត់ បន្ថែម លុបចោល កែប្រែអត្តន័យ ផ្អាក បញ្ឈប់ មុខងារទាំងអស់ ឬ មួយផ្នែកនៃ Hotlineសម្រាប់ដៃគូអាជីវកម្មបាន។
5. អ៊ីអននិងASSC មានសិទ្ធិប្រើ ព័ត៌មានផ្សេងៗនៅលើ "Hotlineសម្រាប់ដៃគូអាជីវកម្ម" បានដោយសេរី ដោយរួមទាំង ការពិគ្រោះយោបល់តាមរយៈ "Hotlineសម្រាប់ដៃគូអាជីវកម្ម"ផង ក្នុងវិសាលភាពដែលអ៊ីអន ឬASSCវិនិច្ឆ័យថាចាំបាច់ ក្នុងគោលបំណងស្វែងរកអាយបានលឿន ឬ កែលម្អបញ្ហាប្រឈមទាក់ទងនឹងសិទ្ធិរបស់ពលករនៅលើខ្សែរចង្វាក់ផ្គត់ផ្គង់ (Supply Chain) ។
6. ទោះបីក្រោយពេលលុបគណនីប្រើប្រាស់ក៏ដោយ អ្នកប្រើប្រាស់យល់ព្រមឲ្យអ៊ីអននិងASSC អាចកាន់កាប់អត្តន័យពិគ្រោះរបស់អ្នកប្រើប្រាស់ ក្នុងគោលបំណងដើម្បីរក្សាបម្រុងទុក (Backup) រក្សាជាបណ្ណសារ (Archives) ឬ សវនកម្ម ក្នុងកំឡុងពេលមួយសមស្រប ហើយថែមទាំងឯកភាព ចំពោះការកាន់កាប់ច្បាប់

ចម្លងនៃបណ្ណសារកំណត់ត្រារបស់អ្នកប្រើប្រាស់ ក្នុងករណីមានកាតព្វកិច្ចកំណត់ដោយច្បាប់ ឬ សម្រាប់គោលបំណងធុរកិច្ចស្របច្បាប់។

មាត្រា ៦ (ការធ្វើការសិក្សាអង្កេត)

1. អ៊ីអន និងASSC មានសិទ្ធិឲ្យអ្នកប្រើប្រាស់ ឆ្លើយ បោះឆ្នោត ឬ ផ្ញើរប្រគល់មកវិញ តាមរយៈអ៊ីម៉ែល ឬគេហទំព័រ ក្នុងទម្រង់ជាលក្ខណៈអង្កេត(សំណួរ) (តទៅនេះ ហៅថា "អង្កេត") តាមពេលវេលាសមគួរណាមួយ ក្នុងគោលបំណងសិក្សាអំពីលក្ខណៈ និន្នាការ ឬមតិយោបល់របស់អ្នកប្រើប្រាស់ ជាដើម។
2. ស្តីពីកម្មសិទ្ធិបញ្ញា ឬ សិទ្ធិផ្សេងៗទៀតរបស់អ្នកនិពន្ធ ដែលកើតឡើងចំពោះចម្លើយអង្កេតរបស់អ្នកប្រើប្រាស់ សិទ្ធិទាំងអស់នោះត្រូវផ្ទេរឲ្យ អ៊ីអន ឬASSC ភ្លាម គ្រាន់តែពេលដែលអ្នកប្រើប្រាស់ផ្ញើរចម្លើយនោះឲ្យ អ៊ីអន ឬASSC ហើយ អ៊ីអន និងASSC មានសិទ្ធិប្រើព័ត៌មាន ដែលមាននៅក្នុងអត្ថន័យចម្លើយនោះ ស្របតាមរបៀបចាត់ចែងទុកដាក់ព័ត៌មានផ្ទាល់ខ្លួន ឬ ព័ត៌មានចុះឈ្មោះដែលមានកំណត់នៅក្នុងមាត្រា៨។

មាត្រា ៧ (ការគ្រប់គ្រងព័ត៌មានសម្ងាត់ និងការកែប្រែព័ត៌មានចុះឈ្មោះ)

1. អ្នកប្រើប្រាស់ Genba-Wise ត្រូវគ្រប់គ្រងព័ត៌មានផ្សេងៗ (តទៅនេះ ហៅថា "ព័ត៌មានសម្ងាត់") ដូចជា ID និង ពាក្យសម្ងាត់ ជាដើម ដែលចាំបាច់សម្រាប់ឲ្យ ASSC ទទួលស្គាល់ និង អនុញ្ញាតឲ្យអ្នកប្រើប្រាស់ចូលប្រើកម្មវិធីបាន ក្នុងបន្ទុកនិងទំនួលខុសត្រូវផ្ទាល់ខ្លួន ហើយមិនត្រូវឲ្យ ផ្ទេរ ស្នងបន្ត ឬបញ្ចាំឲ្យទៅតតិយជន ឬ បោះចោលក្នុងរបៀបណាមួយទេ លើសពីនេះទៀត មិនត្រូវបង្ហាញជាសាធារណៈឡើយ ។
2. ចំពោះការខូចប្រយោជន៍ផ្សេងៗ ដោយសារការលេចធ្លាយព័ត៌មានសម្ងាត់ ដែលអ្នកប្រើប្រាស់ Genba-Wise មិនបានគ្រប់គ្រងឲ្យបានគ្រប់ជ្រុងជ្រោយ, កំហុសឆ្គងក្នុងការប្រើប្រាស់, ការប្រើប្រាស់ដោយតតិយជន និង ការលួចចូលប្រើដោយគ្មានការអនុញ្ញាត អ្នកប្រើប្រាស់ជាអ្នកទទួលខុសត្រូវទាំងស្រុង ចំណែកឯ អ៊ីអន និង ASSC គ្មានទំនួលខុសត្រូវណាមួយឡើយ លើកលែងករណី អ៊ីអន ឬASSC មានការធ្វេសប្រហែសដោយចេតនា។ ចែដន្យ ករណីព័ត៌មានសម្ងាត់នោះត្រូវបានគេយកទៅប្រើខុស ហើយបណ្តាលឲ្យមានការខូចប្រយោជន៍ដល់ អ៊ីអន, ASSCឬតតិយជន អ្នកប្រើប្រាស់ត្រូវទទួលខុសត្រូវសងជម្ងឺចិត្តដល់ផលប៉ះពាល់ពាក់ព័ន្ធនោះ។
3. ករណីមានការកែប្រែព័ត៌មានចុះឈ្មោះ, ព័ត៌មានសម្ងាត់ត្រូវបានលេចឮដល់តតិយជន ឬ មានការសង្ស័យព័ត៌មានសម្ងាត់ត្រូវបានប្រើដោយតតិយជន អ្នកប្រើប្រាស់ Genba-Wise ត្រូវជូនដំណឹងអំពីករណីនេះ ដល់អ៊ីអន ឬASSCជាបន្ទាន់ តាមនីតិវិធីកំណត់ដោយASSC និងកិច្ចព្រមព្រៀងនេះ ហើយទន្ទឹមនឹងគ្នានេះដែរ ត្រូវចាត់វិធានការចាំបាច់ ដែលអាចធ្វើទៅបាន ដើម្បីជៀសវាងកុំឲ្យតតិយជនបន្តប្រើព័ត៌មានសម្ងាត់តទៅទៀត។ ដោយឡែក ករណីមានការណែនាំពីអ៊ីអន ឬASSC អ្នកប្រើប្រាស់ត្រូវតែគោរពធ្វើតាមសេចក្តីណែនាំនោះ។
4. ករណីអ្នកប្រើប្រាស់ Genba-Wise ត្រូវខូចប្រយោជន៍ ដោយសារមិនបានចាត់វិធានការតាមការណែនាំ នៅក្នុងកថាខណ្ឌខាងលើ អ៊ីអននិងASSC គ្មានទំនួលខុសត្រូវណាមួយឡើយ លើកលែងតែករណី អ៊ីអន ឬ ASSC មានការធ្វេសប្រហែសដោយចេតនា ។
5. ករណីអ្នកប្រើប្រាស់ Genba-Wise ឥតបានធ្វើការទាក់ទង ដូចមានចែងនៅក្នុងកាថាខណ្ឌទី3 នៃមាត្រានេះ អ៊ីអន និងASSC អាចចាត់ទុកថា អ្នកប្រើប្រាស់ពាក់ព័ន្ធនោះ បានលាលែង និង ឈប់ប្រើកម្មវិធីនេះហើយ។

មាត្រា ៨ (ព័ត៌មានចុះឈ្មោះ និង ព័ត៌មានផ្ទាល់ខ្លួន)

1. អ៊ីអន និងASSC នឹងប្រើព័ត៌មានចុះឈ្មោះ ក្នុងគោលបំណងដូចខាងក្រោម៖
   (1) ដើម្បីដំណើរការ "Hotlineសម្រាប់ដៃគូអាជីវកម្ម" (រួមទាំង ព័ត៌មានទាំងឡាយ ដែលASSC ផ្តល់ឲ្យអ៊ីអន ឬអ្នកប្រើប្រាស់)
   (2) ដើម្បីផ្តល់ជូនសេវារបស់ អ៊ីអន ឬASSC ដែល អ៊ីអនឬASSC វិនិច្ឆ័យថាមានប្រយោជន៍ដល់អ្នកប្រើប្រាស់(ដោយមិនកម្រិតត្រឹមតែ "Hotlineសម្រាប់ដៃគូអាជីវកម្ម" តែប៉ុណ្ណោះទេ) ឬដើម្បីផ្តល់ជូននូវព័ត៌មានទាក់ទងនឹងផលិផល សេវា។ល។របស់ក្រុមហ៊ុនដៃគូ ឬ អ្នកផ្សាយពានិជ្ជកម្ម
   (3) ដើម្បីធ្វើការសិក្សាអង្កេត និងវិភាគលទ្ធផលពាក់ព័ន្ធ ដើម្បីគ្រប់គ្រងគុណភាព "Hotlineសម្រាប់ដៃគូអាជីវកម្ម"
   (4) ដើម្បីធ្វើការទាក់ទងអ្នកប្រើប្រាស់ អំពីប្រការផ្សេងៗដែលមានឥទ្ធិពលគួរកត់សំគាល់ ដល់ដំណើរការនៃ "Hotlineសម្រាប់ដៃគូអាជីវកម្ម" (ដែលរួមទាំង ការកែប្រែអត្ថន័យនៃ "Hotlineសម្រាប់ដៃគូអាជីវកម្ម"គួរកត់សំគាល់ ការផ្អាកបណ្តោះអាសន្ន ក៏ប៉ុន្តែមិនកម្រិតត្រឹមតែប៉ុណ្ណោះទេ)
   (5) ដើម្បីទាក់ទងអ្នកប្រើប្រាស់ ដើម្បីសុំការឯកភាពយល់ព្រមចំពោះការចាត់ចែងទុកដាក់ព័ត៌មានផ្ទាល់ខ្លួន

2. អ្នកប្រើប្រាស់យល់ព្រម ឲ្យអ៊ីអន និងASSCបញ្ចេញព័ត៌មានចុះឈ្មោះ ដល់តតិយជន ក្រៅពីសាមីខ្លួនបាន ក្នុងករណីដូចខាងក្រោម៖
   (1) ករណីធ្វើការប្រមូល និង វិភាគព័ត៌មានចុះឈ្មោះ ក្នុងគោលបំណងលើកកម្ពស់សេវា "Hotlineសម្រាប់ដៃគូអាជីវកម្ម" ឬ សេវាពាក់ព័ន្ធ ឬដើម្បីអភិវឌ្ឍគម្រោងពាក់ព័ន្ធ
   (2) ករណីផ្តល់ឲ្យ ឬ បង្ហាញទៅតតិយជន នូវអ្វីដែលជាលទ្ធផលនៃការប្រមូល និងវិភាគនៅក្នុងកថាខណ្ឌខាងលើ ក្នុងទម្រង់ដែលមិនអាចកំណត់អត្តសញ្ញាណបុគ្គលពាក់ព័ន្ធបាន
   (3) ករណីមានការយល់ព្រម ពីសាមីខ្លួនអ្នកប្រើប្រាស់ដែលជាម្ចាស់ព័ត៌មានផ្ទាល់ខ្លួនពាក់ព័ន្ធនោះ អនុញ្ញាតឲ្យបង្ហាញ ឬ ប្រើព័ត៌មានចុះឈ្មោះ
   (4) ករណីគេទទួលស្គាល់ថា ចាំបាច់ត្រូវតែបង្ហាញ ឬ ប្រើព័ត៌មានចុះឈ្មោះ ដើម្បីផ្តល់សេវាដែលជាសេចក្តីបំណងរបស់អ៊ីអន ឬអ្នកប្រើប្រាស់
   (5) ករណីតតិយជន ដូចជាដៃគូសហការ។ល។ ចាំបាច់ត្រូវការប្រើឬឲ្យបើកចំហព័ត៌មានចុះឈ្មោះ ក្នុងគោលបំណងផ្តល់សេវាដែលជាវត្ថុបំណងរបស់អ៊ីអន ឬអ្នកប្រើប្រាស់ (ចំណែកឯ តតិយជនដែលជាដៃគូពាក់ព័ន្ធ មិនអាចប្រើប្រាស់ព័ត៌មានចុះឈ្មោះដែល ASSC ផ្តល់ឲ្យ ហួសដែនកំណត់បានឡើយ ពោលគឺសម្រាប់តែការផ្តល់សេវាតែប៉ុណ្ណោះ)
   (6) ករណីអនុលោមតាមច្បាប់ និង បទប្បញ្ញត្តិនានា
   (7) ករណីត្រូវការចាំបាច់ សម្រាប់ការពារអាយុជីវិត សរីរាង្គកាយ ឬទ្រព្យសម្បត្តិរបស់ ASSC អ៊ីអន អ្នកប្រើប្រាស់ ព្រមទាំងតតិយជន ឬ ដើម្បីការពារគ្រប់សេវាទាំងអស់ដែលផ្តល់ឲ្យដោយអ៊ីអន ឬASSC
   (8) ករណីត្រូវការជាពិសេស សម្រាប់លើកកម្ពស់សុខភាពសាធារណៈ ឬ ជម្រុញការបណ្តុះបណ្តាលក្មេងៗប្រកបដោយសុខភាពល្អ

(9) ករណីត្រូវការកិច្ចសហការ ក្នុងកិច្ចការដែលស្ថាប័នរដ្ឋ ឬអង្គភាពសាធារណៈតាមមូលដ្ឋាន ឬ បុគ្គលជាប់កិច្ចសន្យាត្រូវបំពេញ តាមការកំណត់ដោយច្បាប់ ឬ បទប្បញ្ញត្តិនានា ឬ ករណីមានសំណើរស្នើរសុំពីបុគ្គល ឬ អង្គភាពទាំងនោះដោយស្របច្បាប់ ឲ្យបង្ហាញនូវព័ត៌មានទាំងនោះ

3. អ៊ីអន និងASSC ត្រូវចាត់ចែងរក្សាទុកដាក់ព័ត៌មានផ្ទាល់ខ្លួន ផ្អែកតាមគោលការណ៍ការពារព័ត៌មានឯកជនភាពនៃHotlineសម្រាប់ដៃគូអាជីវកម្មរបស់អ៊ីអន។
4. អ្នកប្រើប្រាស់ មានសិទ្ធិស្នើរសុំឲ្យបង្ហាញ លុប កែតម្រូវ ឬបញ្ឈប់ការប្រើប្រាស់ ព័ត៌មានចុះឈ្មោះ ហើយអ៊ីអនត្រូវឆ្លើយតបនឹងសំណើរនោះភ្លាម ដោយមិនពន្យាពេល ក្នុងករណីបានពិនិត្យបញ្ជាក់ថា សំណើរនោះ ពិតជាសំណើររបស់សាមីខ្លួនមែន។

## មាត្រា ៩ (ការផ្អាកការប្រើប្រាស់។ល។)

1. ករណីអ៊ីអនវិនិច្ឆ័យថា អ្នកប្រើប្រាស់ស្ថិតនៅក្នុង ឬ មានហានិភ័យអាចធ្លាក់ទៅក្នុងស្ថានភាពណាមួយដូចខាងក្រោម អ៊ីអន មានឆន្ទានុសិទ្ធិក្នុងការជូនដំណឹងសម្រេចផ្អាកការប្រើប្រាស់ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ទាំងស្រុងឬមួយផ្នែកភ្លាម ដោយមិនចាំបាច់ជូនដំណឹងទុកជាមុននិងសុំការឯកភាពយល់ព្រមពីអ្នកប្រើប្រាស់ទេ ចំពោះអ្នកប្រើប្រាស់ពាក់ព័ន្ធ ថែមទាំមិនត្រូវការសុំការយល់ព្រមពីអ្នកប្រើប្រាស់ ហើយបន្ថែមពីលើនេះទៀត អ៊ីអនមានសិទ្ធិចាត់វិធានការដែលយល់ឃើញថាសមស្របបាន។ ដោយឡែក ករណី អ៊ីម៉ែល(E-mail) ដែលបានប្រើក្នុងព័ត៌មានចុះឈ្មោះ ឥតដំណើរការ ប្រសិនបើវិធានការទាំងនេះត្រូវបានអនុវត្តរួចហើយនោះក៏ចាត់ទុកថាបានជូនដំណឹងដល់អ្នកប្រើប្រាស់ពាក់ព័ន្ធរួចហើយដែរ។
   (1) ករណីប្រព្រឹត្តបទបំពានកិច្ចព្រមព្រៀងនេះ
   (2) ករណីមានការក្លែងបន្លំ ឬ កំហុសក្នុងព័ត៌មានចុះឈ្មោះ
   (3) ករណី អ៊ីម៉ែល (E-mail) ដែលបានប្រើក្នុងព័ត៌មានចុះឈ្មោះ ត្រូវបានសន្និដ្ឋានថា ឥតដំណើរការ
   (4) ករណី បានធ្វើការចុះឈ្មោះប្រើប្រាស់ Genba-Wise ដោយក្លែងជាតតិយជន
   (5) ករណីអ្នកប្រើប្រាស់ បានលាលែងពីការងារនៅក្រុមហ៊ុនចុះកិច្ចសន្យាបន្តពីអ៊ីអន
   (6) ករណីអ្នកប្រើប្រាស់បានស្លាប់
   (7) បន្ថែមពីលើនេះទៀត ករណី អ៊ីអន វិនិច្ឆ័យថា មិនសមជាអ្នកប្រើប្រាស់ទេ
2. ករណី អ៊ីអនឬASSC ទទួលរងនូវការខូចប្រយោជន៍ណាមួយ ដោយសារករណីក្នុងកថាខណ្ឌខាងលើ អ្នកប្រើប្រាស់ត្រូវសងសំណងជម្ងឺចិត្តពាក់ព័ន្ធ ដល់ អ៊ីអនឬASSC ។
3. ASSC គ្មានកាតព្វកិច្ច បង្ហាញនូវមូលហេតុថា ហេតុអ្វីត្រូវចាត់វិធានការដូចមានចែងនៅក្នុងកាថាខណ្ឌទី1 ដល់អ្នកប្រើប្រាស់ទេ ។

## មាត្រា ១០ (កម្មសិទ្ធិបញ្ញា ។ល។)

1. រាល់សិទ្ធិអ្នកនិពន្ធទាំងអស់ ដែលកើតចេញពី ឃ្លោងឃ្លា រូបភាព វីដេអូ ប្រ៉ូក្រាម(Program) និងព័ត៌មានផ្សេងៗ ដែលជាសមាសធាតុនៃ "Hotlineសម្រាប់ដៃគូអាជីវកម្ម" រួមទាំង Genba-Wise ផង (រួមទាំងសិទ្ធិដែលមានចែងនៅក្នុងមាត្រា ២៧ ឬ មាត្រា ២៨ នៃច្បាប់ស្ដីពីសិទ្ធិអ្នកនិពន្ធ) និងកម្មសិទ្ធិបញ្ញាផ្សេងៗ, សិទ្ធិលើ

រូបមនុស្សពិត (Portrait) ក៏ដូចជាសិទ្ធិផ្សព្វផ្សាយ សិទ្ធិសីលធម៌ ព្រមទាំងម្ចាស់កម្មសិទ្ធិ និង កម្មសិទ្ធិលើទ្រព្យសម្បត្តិផង ជាកម្មសិទ្ធិរបស់ អ៊ីអនឬASSC។

2. អ៊ីអននិងASSCអាចចម្លងទុក និងប្រមូលទុក រាល់ព័ត៌មានទាំងអស់ដែលអ្នកប្រើប្រាស់បានចុះផ្សាយ (Post)ឬបង្ហោះ(Upload)នៅតាម "Hotlineសម្រាប់ដៃគូអាជីវកម្ម" (រួមទាំង អត្ថបទណែនាំ អត្ថន័យ។ល។ ដែលបានចុះផ្សាយនៅលើប្រព័ន្ធផ្សព្វផ្សាយរបស់តតិយជន) ហើយបន្ថែមពីលើនេះទៀត ក៏អាចបកប្រែ និងប្រើព័ត៌មានទាំងនោះ ក្នុងទម្រង់ផ្សេងៗ ក្នុងគោលបំណងសម្រាប់ដំណើរការឲ្យបានរលូន និងការកែលម្អ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ក៏ដូចជាដើម្បីជូនដំណឹងអំពីការផ្សព្វផ្សាយអំពី "Hotlineសម្រាប់ដៃគូអាជីវកម្ម" (រួមទាំង អត្ថបទឬអត្ថន័យចែករំលែកណែនាំ ។ល។ដែលបានចុះផ្សាយនៅលើប្រព័ន្ធព័ត៌មានរបស់តតិយជន) ហើយសន្មត់ថា អ្នកប្រើប្រាស់ឯកភាពយល់ព្រមចំពោះចំណុចនេះ។
3. អ្នកប្រើប្រាស់ យល់ព្រមមិនអនុវត្តសិទ្ធិសីលធម៌ជាអ្នកនិពន្ធ ចំពោះបុគ្គលណាដែលបានទទួលបានសិទ្ធិស្នងបន្ត ឬការអនុញ្ញាតពី អ៊ីអន, ASSC ព្រមទាំងASSC។
4. ករណីមានបញ្ហារំលោភសិទ្ធិតតិយជន ពាក់ព័ន្ធនឹងស្នាដៃរបស់ខ្លួន អ្នកប្រើប្រាស់ត្រូវទទួលខុសត្រូវដោះស្រាយបញ្ហានោះ ក្នុងបន្ទុកចំណាយផ្ទាល់ខ្លួន ហើយមិនត្រូវបង្កឲ្យការខូចប្រយោជន៍ ឬ ផលប៉ះពាល់រំខានណាមួយ ដល់អ៊ីអននិងASSC ឡើយ។

## មាត្រា ១១ (ប្រការហាមឃាត់)

1. អ្នកប្រើប្រាស់ មិនត្រូវប្រព្រឹត្តិអំពើដែលហាមឃាត់ដូចខាងក្រោមទេ។
   (1) ការប្រកាសដោយភូតកុហក
   (2) អំពើដែលរំខានដល់ដំណើរការនៃ "Hotlineសម្រាប់ដៃគូអាជីវកម្ម"
   (3) អំពើដែលរំលោភសិទ្ធិ ឬ អំពើដែលបង្ករបួសស្នាម ឬ ប៉ះពាល់ដល់កិត្តិយសរបស់អ្នកប្រើប្រាសផ្សេងទៀត ឬ អ្នកប្រើប្រាស់, អ៊ីអន, ASSC និងតតិយជន
   (4) ករណីអ្នកប្រើប្រាស់ បំពានចំនុចណាមួយនៃចំនុចហាមឃាត់ ដែលបានចែងនៅក្នុងកថាខណ្ឌខាងលើ អ៊ីអននិងASSC មានសិទ្ធិទាមទារសំណងជម្ងឺចិត្តពីអ្នកប្រើប្រាស់ពាក់ព័ន្ធ ចំពោះផលប៉ះពាល់ផ្សេងៗ (រួមទាំងថ្លៃសមស្របដែលចំណាយលើមេធាវី)ដែល អ៊ីអនឬASSC ទទួលរង ដោយសារអំពើទាំងនោះ។

## មាត្រា ១២ (ការផ្អាក បញ្ឈប់ និងបិទកម្មវិធី **"Hotline**សម្រាប់ដៃគូអាជីវកម្ម")

1. អ៊ីអន មានសិទ្ធិផ្អាក "HOTLINEសម្រាប់ដៃគូអាជីវកម្ម" ទាំងស្រុងឬមួយផ្នែក ក្នុងករណីមានហេតុផលណាមួយដូចខាងក្រោមកើតឡើង។
   (1) ករណីអ៊ីអនឬASSC ត្រូវធ្វើការត្រួតពិនិត្យថែទាំ ប្រព័ន្ធកុំព្យូទ័រ ជាបន្ទាន់ ឬតាមពេលកំណត់ ដើម្បីធានាបាននូវការផ្តល់សេវា "Hotlineសម្រាប់ដៃគូអាជីវកម្ម"
   (2) ករណី "HOTLINEសម្រាប់ដៃគូអាជីវកម្ម" មិនអាចំណើរការបាន ដោយសារស្ថានភាពមិនប្រក្រតី ដូចជា ករណីអគ្គីភ័យ ដាច់ចរន្តអគ្គិសនី គ្រោះមហន្តរាយធម្មជាតិ។ល។

(3) ករណី "Hotlineសម្រាប់ដៃគូអាជីវកម្ម" មិនអាចំណើរការបាន ដោយសារតែមានសង្គ្រាម ភាពបះបោលស៊ីវិល កុប្បកម្ម ចលាចល វិវាទការងារ។ល។

(4) ករណី "Hotlineសម្រាប់ដៃគូអាជីវកម្ម" មិនអាចដំណើរការបាន ដោយសារតែ ប្រព័ន្ធកុំព្យូទ័រដែលប្រើសម្រាប់ផ្តល់សេវានោះខូច, មានតតិយជនលួចចូលប្រើដោយគ្មានការអនុញ្ញាត ឬករណីមានការឆ្លងមេរោគចូលក្នុងកុំព្យូទ័រ។ល។

(5) ករណីមិនអាចផ្តល់សេវា "Hotlineសម្រាប់ដៃគូអាជីវកម្ម" ឬ សេវាអ្នកប្រើប្រាស់បាន ដោយសារតែការចាត់វិធានការអនុលោមតាមច្បាប់ ឬបទប្បញ្ញត្តិ នានា

(6) បន្ថែមពីលើនេះទៀត ករណី អ៊ីអនឬASSC វិនិច្ឆ័យថា មិនអាចជៀសវាងបាន

(7) ករណីមានការផ្អាកដំណើរការ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ដោយសារមូលហេតុដូចមានចែងក្នុងកថាខណ្ឌខាងលើ អ៊ីអន ត្រូវជូនដំណឹងដល់អ្នកប្រើប្រាស់ ស្តីពីប្រការនោះ តាមរយៈអ៊ីម៉ែល(E-mail) ឬមធ្យោបាយផ្សេងៗ ក្នុងកម្រិតមួយសមរម្យ។ ក៏ប៉ុន្តែ ក្នុងករណីអាសន្ន មិនកម្រិតតែអញ្ចឹងទេ។

## មាត្រា ១៣ (អញ្ញត្រកម្ម)

1. អ៊ីអននិងASSC មិនធានាថា៖ ព័ត៌មានណាមួយដែលមានបង្កប់នៅក្នុង "Hotlineសម្រាប់ដៃគូអាជីវកម្ម" មានភាពស្របច្បាប់ ភាពត្រឹមត្រូវ ភាពសមស្រប សុពលភាព សីលធម៌ ឬអាជ្ញាប័ណ្ណ ឬទេនោះឡើយ។
2. អ៊ីអននិងASSC គ្មានទំនួលខុសត្រូវណាមួយឡើយ ចំពោះជម្លោះដែលកើតឡើងរវាងអ្នកប្រើប្រាស់ដូចគ្នា ឬរវាងអ្នកប្រើប្រាស់និងតតិយជន (ការលើកសំណើរនូវអំពើដែលបំពានច្បាប់ ឬសីលធម៌សណ្តាប់ធ្នាប់សាធារណៈ, ការខូចកិត្តិយស, ការប្រមាថមើលងាយ, ការបំពានលើឯកជនភាព, ការគម្រាមកំហែង, និយាយបរិហារកេរ្តិ៍, ការរំលោភបំពាន ។ល។) នាពេលប្រើ "Hotlineសម្រាប់ដៃគូអាជីវកម្ម" លើកលែងករណី អ៊ីអនឬASSCមានការធ្វេសប្រហែសដោយចេតនា។
3. អ៊ីអននិងASSC ក៏គ្មានទំនួលខុសត្រូវណាមួយឡើយ ចំពោះការខូចប្រយោជន៍ដល់អ្នកប្រើប្រាស់ដែលកើតឡើង ដោយសារការផ្អាក ការបញ្ឈប់ ការបិទកម្មវិធី "Hotlineសម្រាប់ដៃគូអាជីវកម្ម" ព្រមទាំងដោយសារការកែប្រែ "Hotlineសម្រាប់ដៃគូអាជីវកម្ម" ដូចមានចែងក្នុងកថាខណ្ឌទី3នៃមាត្រានេះ (រួមទាំងការខូចប្រយោជន៍ដោយសារការបាត់បង់ព័ត៌មាននានា ហើយក៏មិនកម្រិតត្រឹមប៉ុណ្ណឹងដែរ) លើកលែងករណី អ៊ីអនឬASSC មានការធ្វេសប្រហែសដោយចេតនា។
4. អ៊ីអននិងASSC ក៏គ្មានទំនួលខុសត្រូវណាមួយឡើយចំពោះការខូចប្រយោជន៍ណាមួយ ដែលបង្កឡើងដោយសារការឆ្លងមេរោគចូលក្នុងកុំព្យូទ័រ ឬ ដោយសារបរិស្ថានប្រើប្រាស់ PC ឧបករណ៍Terminalទំនើបឆ្លាតឧបករណ៍Terminalយួរដៃ ខ្សែណេតវើក (Line), សូហ្វវែរ (Software)។ល។ របស់អ្នកប្រើប្រាស់ប្រើ ។ អ៊ីអននិងASSC អាចជូនដំណឹងដល់អ្នកប្រើប្រាស់អំពីបរិស្ថានប្រើប្រាស់ពាក់ព័ន្ធ តាមមធ្យោបាយដាក់លាក់ដោយឡែកបាន។
5. អ៊ីអន និងASSC ក៏គ្មានទំនួលខុសត្រូវណាមួយឡើយ ចំពោះការខូចប្រយោជន៍ទាំងឡាយណាដែលកើតឡើងដល់អ្នកប្រើប្រាស់ ដោយមូលហេតុដែលបានចែងនៅក្នុងកថាខណ្ឌនីមួយៗខាងលើ និងដោយសារការប្រើ "Hotlineសម្រាប់ដៃគូអាជីវកម្ម" លើកលែងករណីអ៊ីអន ឬASSCមានការធ្វេសប្រហែសដោយចេតនា។

## មាត្រា 14 (កិច្ចពិភាក្សា តុលាការមានសមត្ថកិច្ច)

1. ករណីមានបញ្ហា ឬ ចម្ងល់ស្តីពីHotlineសម្រាប់ដៃគូអាជីវកម្ម កើតឡើងរវាង អ្នកប្រើប្រាស់, អ៊ីអន, ASSC និង តតិយជន ត្រូវតែដោះស្រាយ ដោយផ្អែកលើការពិភាក្សាយល់ព្រម ដោយស្មោះត្រង់រវាងគ្នានិងគ្នា។
2. ស្តីអំពីបណ្តឹងណាមួយ ឬវិវាទផ្សេងៗស្តីពីកិច្ចព្រមព្រៀងនេះ តុលាការទីក្រុងតូក្យូ ( Tokyo Summary Court) ឬតុលាការដំបូងទីក្រុងតូក្យូ(Tokyo District Court) ជាតុលាការមានសមត្ថកិច្ចសម្រេចសាលក្រមផ្តាច់មុខក្នុងសវនាការលើកដំបូង។

## មាត្រា 15 (ច្បាប់ដែលមានអនុភាព)

កិច្ចព្រមព្រៀងនេះ អនុលោមតាមច្បាប់និងបទប្បញ្ញត្តិជាធរមានរបស់ប្រទេសជប៉ុន និងត្រូវបកស្រាយដោយយោងតាមច្បាប់របស់ប្រទេសជប៉ុន។